ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ២១ ៤ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## បែបបទនិងនីតិវិធីនៃការប្តឹង និងការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម

## រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៥ អនក្រ.បក ចុះថ្ងៃទី២៥ ខែឧសភា ឆ្នាំ២០១៧ ស្តីពីការកែសម្រួលអនុក្រឹត្យលេខ ៤៨៨ ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលបំណងធានាឱ្យការដោះស្រាយបណ្ដឹងតវ៉ាពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈប្រព្រឹត្តទៅដោយសុច្ចរិត យុត្តិធម៌ អព្យាក្រឹត្យ និងគ្មានការរើសអើង ដើម្បីជំរុញឱ្យដំណើរការនៃកិច្ចលទ្ធកម្មសាធារណៈប្រព្រឹត្តទៅដោយរលូន ប្រកបដោយតម្លាភាព គណនេយ្យភាព យុត្តិធម៌ ប្រសិទ្ធភាព គុណភាព សមភាព ការសន្សំសំចៃ និងភាពទាន់ពេល។

**មាត្រា២.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីបែបបទ នីតិវិធីនិងយន្តការសម្រាប់ការប្ដឹង និងដោះស្រាយបណ្ដឹងតវ៉ាពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៣.-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះគ្រប់បណ្ដឹងតវ៉ាដែលពាក់ព័ន្ធនឹងកិច្ចលទ្ធកម្មសាធារណៈ នៅក្នុងព្រះរាជាណាចក្រកម្ពុជា លើកលែងតែបណ្ដឹងតវ៉ាពាក់ព័ន្ធដូចខាងក្រោម÷

- កិច្ចលទ្ធកម្មក្រោមគម្រោងហិរញ្ញប្បទានដោយដៃគូអភិវឌ្ឍន៍ ដែលបានកំណត់រួចជាស្រេចនូវបែបបទ នីតិវិធី និងយន្តការសម្រាប់ដោះស្រាយបណ្ដឹងតវ៉ា ដូចមានចែងក្នុងកិច្ចព្រមព្រៀងហិរញ្ញប្បទាន។ ប្រសិនបើកិច្ចព្រមព្រៀងមិនបានកំណត់អំពីបែបបទ នីតិវិធី និងយន្តការសម្រាប់ដោះស្រាយបណ្ដឹងតវ៉ាទេ បែបបទ នីតិវិធី និងយន្តការសម្រាប់ដោះស្រាយបណ្ដឹងតវ៉ា ត្រូវអនុវត្តតាមបទប្បញ្ញត្តិ នៃអនុក្រឹត្យនេះ។
- កិច្ចលទ្ធកម្មដែលប៉ះពាល់ដល់ការសម្ងាត់ក្នុងវិស័យការពារជាតិ និងសន្តិសុខសាធារណៈដែលត្រូវមានការសម្រេចពីនាយករដ្ឋមន្ត្រី។
- កិច្ចលទ្ធកម្មក្រោមគម្រោងសម្បទានផ្សេងៗរបស់រដ្ឋ ដែលត្រូវអនុលោមតាមច្បាប់និងបទប្បញ្ញត្តិដោយឡែក។

**មាត្រា៤.-**

និយមន័យនៃបច្ចេកសព្ទដែលប្រើប្រាស់ក្នុងអនុក្រឹត្យនេះ ត្រូវបានកំណត់ដូចខាងក្រោម÷

- អ្នកដេញថ្លៃ សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានបំណងចូលរួមក្នុងកិច្ចលទ្ធកម្មសាធារណៈ និងបានដាក់សំណើដេញថ្លៃឬសំណើចំណាប់អារម្មណ៍។
- អ្នកដេញថ្លៃសក្ដានុពល សំដៅដល់រូបវន្តបុគ្គលឬនីតិបុគ្គលដែលមានបំណងចូលរួមក្នុងកិច្ចលទ្ធកម្មសាធារណៈ។
- បណ្ដឹងតវ៉ា សំដៅដល់ការទាមទារឬការតវ៉ារបស់អ្នកដេញថ្លៃអំពីដំណើរការលទ្ធកម្មសាធារណៈដែលមានភាពមិនប្រក្រតីមុនពេលចុះកិច្ចសន្យាលទ្ធកម្ម។
- អំពើបន្លំ សំដៅដល់ការបកស្រាយបំភ្លៃហេតុការណ៍ដើម្បីធ្វើឱ្យមានឥទ្ធិពលលើដំណើរការលទ្ធកម្មសាធារណៈ។
- អំពើឃុបឃិត សំដៅដល់ផែនការឬការរៀបចំឡើងរវាងអ្នកដេញថ្លៃពីរឬច្រើននាក់ ដើម្បីបង្កើតតម្លៃដេញថ្លៃសិប្បនិម្មិតគ្មានលក្ខណៈប្រកួតប្រជែងពិតប្រាកដ ឬធ្វើឱ្យមានឥទ្ធិពលលើសកម្មភាពរបស់ភាគីណាមួយ ក្នុងដំណើរការលទ្ធកម្មសាធារណៈឬធ្វើឱ្យមានការជះឥទ្ធិពលលើការអនុវត្តកិច្ចសន្យា។
- អំពើបង្ខិតបង្ខំ សំដៅដល់ការហាមឃាត់ឬការគម្រាមកំហែងដោយផ្ទាល់ឬដោយប្រយោលធ្វើឱ្យមានគ្រោះថ្នាក់ដល់បុគ្គលឬទ្រព្យសម្បត្តិរបស់បុគ្គលដើម្បីធ្វើឱ្យមានឥទ្ធិពលដល់ការចូលរួមក្នុងដំណើរការលទ្ធកម្មសាធារណៈរបស់បុគ្គលនោះឬធ្វើឱ្យមានការជះឥទ្ធិពលលើការអនុវត្តកិច្ចសន្យា។

## ជំពូកទី២
## បែបបទនិងនីតិវិធីនៃការដាក់ពាក្យប្តឹងតវ៉ា

**មាត្រា៥.-**

អ្នកដេញថ្លៃសក្តានុពលនិងអ្នកដេញថ្លៃដែលបានចូលរួមក្នុងកិច្ចលទ្ធកម្មសាធារណៈ មានសិទ្ធិប្តឹងតវ៉ាពីភាពមិនប្រក្រតីដែលអាចកើតមានឡើងក្នុងដំណើរការលទ្ធកម្មសាធារណៈតាមលំដាប់លំដោយទៅស្ថាប័នអនុវត្តលទ្ធកម្មដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។ អ្នកដេញថ្លៃសក្តានុពលមានសិទ្ធិប្តឹងតវ៉ាក្នុងដំណាក់កាលនៃការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ និងដំណាក់កាលនៃការលក់ឬការផ្តល់ឯកសារដេញថ្លៃ។ អ្នកដេញថ្លៃដែលបានចូលរួមក្នុងកិច្ចលទ្ធកម្មសាធារណៈមានសិទ្ធិប្តឹងគ្រប់ដំណាក់កាលនៃកិច្ចលទ្ធកម្មសាធារណៈមុនពេលចុះកិច្ចសន្យា។

ការប្តឹងក្រោយពេលចុះកិច្ចសន្យាត្រូវធ្វើឡើងដោយភាគីហត្ថលេខីនៃកិច្ចសន្យា និងត្រូវអនុវត្តតាមលក្ខខណ្ឌដែលមានចែងក្នុងកិច្ចសន្យា។

**មាត្រា៦.-**

អ្នកដេញថ្លៃអាចប្តឹងតវ៉ាចំពោះភាពមិនប្រក្រតីណាមួយពាក់ព័ន្ធនឹងករណីជាអាទិ៍ ÷

- ការកំណត់លក្ខណសម្បត្តិអ្នកដេញថ្លៃ
- ការផ្សព្វផ្សាយសេចក្តីជូនដំណឹងស្តីពីការដេញថ្លៃ
- ការលក់ ឬផ្តល់ឯកសារដេញថ្លៃ
- ការទទួលសំណើដេញថ្លៃ និងការបើកសំណើដេញថ្លៃ
- ការមិនអនុញ្ញាតឱ្យអ្នកដេញថ្លៃចូលរួមក្នុងដំណើរការកិច្ចលទ្ធកម្មសាធារណៈ
- ការសម្រេចប្រគល់កិច្ចសន្យា។

**មាត្រា៧.-**

អ្នកដេញថ្លៃមិនអាចប្តឹងតវ៉ាពាក់ព័ន្ធនឹងករណីណាមួយជាអាទិ៍ ÷

- បណ្តឹងតវ៉ាទាមទារឱ្យមានការពន្យល់ពីមូលហេតុនៃការជ្រើសរើសវិធីសាស្ត្រលទ្ធកម្មនីមួយៗ ឬពីផែនការលទ្ធកម្ម
- បណ្តឹងតវ៉ាក្នុងគោលបំណងធ្វើឱ្យមានការកែប្រែ ឬរំខាន ឬបង្អាក់ ឬពន្យារពេលដំណើរការនៃកិច្ចលទ្ធកម្ម
- បណ្តឹងតវ៉ាពុំមានមូលដ្ឋានច្បាប់ច្បាស់លាស់។

**មាត្រា៨.-**

ពាក្យប្តឹងតវ៉ា ត្រូវធ្វើជាលាយលក្ខណ៍អក្សរ ដោយត្រូវមានចុះហត្ថលេខានិងត្រា ឬស្នាមមេដៃ ឈ្មោះ អាសយដ្ឋានរបស់អ្នកប្តឹងតវ៉ា។ អ្នកប្តឹងត្រូវភ្ជាប់មកជាមួយនូវព័ត៌មាន ឬឯកសារភស្តុតាងជាលាយលក្ខណ៍អក្សរ និងឯកសារចាំបាច់ផ្សេងៗទៀត។ ពាក្យប្តឹងតវ៉ាត្រូវបញ្ជាក់អំពីចំណុចសំខាន់ៗដូចខាងក្រោម÷

- កម្មវត្ថុនៃការប្តឹង
- ឈ្មោះគម្រោង
- ម្ចាស់គម្រោង
- ភាពមិនប្រក្រតីដែលបានកើតឡើងក្នុងដំណាក់កាលណាមួយនៃកិច្ចលទ្ធកម្មសាធារណៈ
- ការរំលោភបំពានលើបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងលទ្ធកម្មសាធារណៈ និង
- ការស្នើសុំដំណោះស្រាយ។

**មាត្រា៩.-**

អ្នកដេញថ្លៃ ត្រូវប្ដឹងតវ៉ាទៅសាមីប្រធានស្ថាប័នអនុវត្តលទ្ធកម្មដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ ក្នុងរយៈពេលនៃដំណាក់កាលលទ្ធកម្មនីមួយៗ ឬយ៉ាងយូរបំផុតត្រឹម ៥(ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីដំណាក់កាលនីមួយៗនៃកិច្ចលទ្ធកម្មសាធារណៈត្រូវបានបញ្ចប់ លើកលែងតែការប្ដឹងតវ៉ាពាក់ព័ន្ធនឹងលទ្ធផលនៃការវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ ដែលអនុញ្ញាតឱ្យអ្នកដេញថ្លៃប្ដឹងតវ៉ាក្នុងរយៈពេល ១០ (ដប់)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទនៃការចេញសេចក្ដីជូនដំណឹងស្ដីពីការសម្រេចប្រគល់កិច្ចសន្យា។ ពាក្យប្ដឹងតវ៉ាដែលដាក់ ឬផ្ញើមកដល់ស្ថាប័នអនុវត្តលទ្ធកម្មដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ក្រោយកាលកំណត់នេះពុំមានសុពលភាពឡើយ។

**មាត្រា១០.-**

បណ្ដឹងតវ៉ាត្រូវបានកត់ត្រា និងរក្សាទុកឱ្យបានត្រឹមត្រូវសម្រាប់ពិនិត្យនិងដោះស្រាយ។ ដំណើរការដោះស្រាយបណ្ដឹងតវ៉ាគឺជាការសម្ងាត់។

## ជំពូកទី៣

## បែបបទនិងនីតិវិធីដោះស្រាយបណ្ដឹងតវ៉ា

### ផ្នែកទី១

### បែបបទនិងនីតិវិធីដោះស្រាយបណ្ដឹងតវ៉ាដោយស្ថាប័នអនុវត្តលទ្ធកម្មដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់

**មាត្រា១១.-**

ស្ថាប័នអនុវត្តលទ្ធកម្មដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ ត្រូវដំណើរការកិច្ចលទ្ធកម្មសាធារណៈជាធម្មតា ទោះបីជាមានការប្ដឹងតវ៉ាពាក់ព័ន្ធនឹងភាពមិនប្រក្រតីណាមួយដែលបានកើតឡើងក្នុងដំណាក់កាលមុនចុះកិច្ចសន្យា លើកលែងតែការប្ដឹងតវ៉ានោះពាក់ព័ន្ធនឹងដំណាក់កាលវាយតម្លៃប្រគល់កិច្ចសន្យា សាមីស្ថាប័នអនុវត្តលទ្ធកម្មដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ត្រូវពន្យារពេលនៃការចុះហត្ថលេខាលើកិច្ចសន្យាលទ្ធកម្ម រហូតដល់បណ្ដឹងតវ៉ានោះត្រូវបានដោះស្រាយចប់នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា១២.-**

ស្ថាប័នអនុវត្តលទ្ធកម្មដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ ត្រូវដោះស្រាយបណ្ដឹងតវ៉ារបស់អ្នកដេញថ្លៃតាមរយៈគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម។ ករណីចាំបាច់ ប្រធានស្ថាប័នអនុវត្តលទ្ធកម្មដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ អាចបង្កើតគណៈកម្មការចំពោះកិច្ចមួយ ដោយអញ្ជើញមន្ត្រីជំនាញនៃអង្គភាពពាក់ព័ន្ធក្រោមឱវាទ ចូលរួមផ្ដល់យោបល់ក្នុងការដោះស្រាយបណ្ដឹងតវ៉ារបស់អ្នកដេញថ្លៃ។

ប្រធាន អនុប្រធាន និងសមាជិកចូលរួមដោះស្រាយបណ្ដឹងតវ៉ាត្រូវប្រកាន់ភ្ជាប់នូវក្រមសីលធម៌លទ្ធកម្ម។ ក្នុងករណីអនុប្រធាន ឬសមាជិកគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម ឬសមាជិកនៃគណៈកម្មការចំពោះកិច្ច ដែលមានទំនាស់ផលប្រយោជន៍ពាក់ព័ន្ធបណ្ដឹងតវ៉ាណាមួយ ត្រូវដកខ្លួនចេញពីដំណើរការនៃការដោះស្រាយបណ្ដឹងតវ៉ានោះ ហើយប្រសិនបើប្រធានគណៈកម្មាធិការលទ្ធកម្មមានទំនាស់ផលប្រយោជន៍ ប្រធានរូបនោះត្រូវចាត់តាំងអនុប្រធាន ឬសមាជិកមួយរូប នៃគណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម ដើម្បីធ្វើជាតំណាងរបស់ខ្លួន សម្រាប់ដោះស្រាយបណ្ដឹងតវ៉ា។

**មាត្រា១៣.-**

ស្ថាប័នអនុវត្តលទ្ធកម្មដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ មានសិទ្ធិបដិសេធ ឬទទួលដោះស្រាយបណ្ដឹងតវ៉ា ដោយត្រូវជូនដំណឹងដល់អ្នកប្ដឹងតវ៉ាក្នុងរយៈពេល ៣(បី)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទនៃការទទួលពាក្យបណ្ដឹងតវ៉ា ដោយត្រូវបញ្ជាក់ពីមូលហេតុច្បាស់លាស់ តាមរយៈលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ដោយផ្ទាល់ដៃ។

**មាត្រា១៤.-**

ចំពោះពាក្យប្ដឹងតវ៉ាដែលពុំមានព័ត៌មានឬឯកសារភ្ជាប់គ្រប់គ្រាន់ គណៈកម្មាធិការលទ្ធកម្ម/ក្រុមលទ្ធកម្ម ត្រូវស្នើឱ្យអ្នកប្ដឹងតវ៉ាផ្ដល់ព័ត៌មានឬឯកសារភស្តុតាងបន្ថែមដើម្បីគាំទ្រលើបណ្ដឹងនោះក្នុងរយៈពេល ៥ (ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីអ្នកប្ដឹងតវ៉ាបានទទួលសេចក្ដីជូនដំណឹងស្ដីពីការទទួលដោះស្រាយបណ្ដឹងតវ៉ា។ ក្នុងករណីហួសរយៈពេលកំណត់ខាងលើ បណ្ដឹងតវ៉ានោះត្រូវចាត់ទុកជាមោឃៈ។

**មាត្រា១៥.-**

ការដោះស្រាយបណ្ដឹងតវ៉ាត្រូវធ្វើឡើងដោយគោរពតាមគោលការណ៍ឯករាជ្យ យុត្តិធម៌ ស្មោះត្រង់ និងមិនទទួលឥទ្ធិពល ឬតាមបញ្ជារបស់ភាគីណាមួយឡើយ។ ការដោះស្រាយបណ្ដឹងតវ៉ា ត្រូវបញ្ជាក់ឱ្យបានច្បាស់លាស់អំពីកម្មវត្ថុនៃការប្ដឹង និងលទ្ធផលនៃការដោះស្រាយបណ្ដឹងតវ៉ា ដោយរួមបញ្ចូលនូវព័ត៌មានដូចខាងក្រោម÷

- មូលហេតុនៃបណ្ដឹងតវ៉ា
- ភស្តុតាងពាក់ព័ន្ធក្នុងការពិនិត្យដោះស្រាយបណ្ដឹងតវ៉ា
- មូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន ក្នុងការធ្វើសេចក្ដីសម្រេច
- សេចក្ដីសម្រេច និងវិធានការអនុវត្តបន្ត។

**មាត្រា១៦.-**

ស្ថាប័នអនុវត្តលទ្ធកម្មដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ ត្រូវពិនិត្យនិងដោះស្រាយបណ្ដឹងតវ៉ាក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទជូនដំណឹងពីការទទួលដោះស្រាយបណ្ដឹងតវ៉ា។ ក្នុងរយៈពេលនេះ ស្ថាប័នអនុវត្តលទ្ធកម្មដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ ត្រូវចាត់ចែងប្រជុំពិភាក្សាដោះស្រាយបណ្ដឹងតវ៉ាដោយមានកំណត់ហេតុប្រជុំ។ កំណត់ហេតុប្រជុំត្រូវចម្លងជូនគ្រប់សមាជិកដែលបានចូលរួមប្រជុំ។ ក្នុងករណីចាំបាច់ស្ថាប័នអនុវត្តលទ្ធកម្មដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ អាចអញ្ជើញអ្នកប្ដឹងតវ៉ា និងភាគីពាក់ព័ន្ធមកបំភ្លឺបន្ថែម។

**មាត្រា១៧.-**

សេចក្ដីសម្រេចលើបណ្ដឹងតវ៉ាត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ ដោយផ្អែកលើច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។ សេចក្ដីសម្រេចនេះ ត្រូវកំណត់អំពីវិធានការពាក់ព័ន្ធមួយចំនួនដែលអាចមានជាអាទិ៍÷

- ការកែតម្រូវឯកសារដេញថ្លៃ ការកំណត់បុរេលក្ខណសម្បត្តិអ្នកដេញថ្លៃ ការផ្សព្វផ្សាយសេចក្ដីជូនដំណឹងស្ដីពីការដេញថ្លៃ ការលក់ឬផ្ដល់ឯកសារដេញថ្លៃ ការទទួលសំណើដេញថ្លៃ ការបើកសំណើដេញថ្លៃ និងការវាយតម្លៃសំណើដេញថ្លៃ
- ការផ្លាស់ប្ដូរសេចក្ដីសម្រេចអនុញ្ញាតឱ្យ ឬការមិនអនុញ្ញាតឱ្យអ្នកដេញថ្លៃ ឬទីប្រឹក្សា ចូលរួមក្នុងដំណើរការកិច្ចលទ្ធកម្មសាធារណៈ
- ការផ្លាស់ប្ដូរសេចក្ដីសម្រេចប្រគល់កិច្ចសន្យាជូនអ្នកដេញថ្លៃ ឬទីប្រឹក្សា។

**មាត្រា១៨.-**

អ្នកប្ដឹងតវ៉ាដែលមិនយល់ព្រមតាមការសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្មដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ ដូចមានចែងក្នុងមាត្រា១៧ នៃអនុក្រឹត្យនេះ មានរយៈពេល ៥ (ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទចេញសេចក្ដីសម្រេចរបស់ស្ថាប័នអនុវត្តលទ្ធកម្មដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ ដើម្បីប្ដឹងបន្តទៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី២
## បែបបទនិងនីតិវិធីដោះស្រាយបណ្តឹងតវ៉ាដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**មាត្រា១៩.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបង្កើតគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មដើម្បីដោះស្រាយបណ្តឹងតវ៉ារបស់អ្នកដេញថ្លៃ។

គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម មានសមាសភាព ដូចតទៅ÷

| | | |
|---|---|---|
| ១- | រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២- | រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ០១រូប | អនុប្រធាន |
| ៣- | អគ្គនាយកនៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ | សមាជិកអចិន្ត្រៃយ៍ |
| ៤- | អគ្គនាយកនៃអគ្គនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងគ្រប់គ្រងបំណុល | សមាជិក |
| ៥- | អគ្គនាយកនៃអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង | សមាជិក |
| ៦- | តំណាងលេខាធិការដ្ឋាននៃក្រុមប្រឹក្សានីតិកម្ម | សមាជិក។ |

សមាសភាពជាក់ស្តែងនៃគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២០.-**

គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មមានសិទ្ធិអញ្ជើញមន្ត្រីជំនាញពាក់ព័ន្ធនៃក្រសួង ស្ថាប័ន តំណាងវិស័យឯកជនពាក់ព័ន្ធ អ្នកប្តឹងតវ៉ាឬភាគីពាក់ព័ន្ធដទៃទៀត ដើម្បីបំភ្លឺឬផ្តល់យោបល់តាមការចាំបាច់។

**មាត្រា២១.-**

នាយកដ្ឋានត្រួតពិនិត្យនិងដោះស្រាយវិវាទ នៃអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ បំពេញមុខងារជាលេខាធិការដ្ឋានរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម ដោយមានភារកិច្ចដូចខាងក្រោម÷

- សម្របសម្រួលការងាររដ្ឋបាល និងធានាកិច្ចដំណើរការរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម
- ទទួល កត់ត្រា និងរក្សាទុកឱ្យបានត្រឹមត្រូវបណ្តឹងតវ៉ារបស់អ្នកដេញថ្លៃ
- ពិនិត្យ និងសិក្សាស្រាវជ្រាវលើបណ្តឹងតវ៉ា ឯកសារ ព័ត៌មាន និងភស្តុតាងពាក់ព័ន្ធ
- តាមការអញ្ជើញរបស់គណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម ធ្វើការជាមួយមន្ត្រីជំនាញពាក់ព័ន្ធនៃក្រសួង ស្ថាប័ន ឬតំណាងវិស័យឯកជនពាក់ព័ន្ធ អ្នកប្តឹងតវ៉ាឬភាគីពាក់ព័ន្ធដទៃទៀត ដើម្បីទទួលបានការបំភ្លឺ ឬការផ្តល់ភស្តុតាងបន្ថែមសម្រាប់ជាមូលដ្ឋាននៃការរៀបចំរបាយការណ៍ជូនប្រធានគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្ម
- លើកសំណើដោះស្រាយបណ្តឹងតវ៉ាជូនប្រធានគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មពិនិត្យ និងសម្រេច
- រៀបចំរបាយការណ៍រាល់ពេលគណៈកម្មាធិការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មប្រជុំពិនិត្យដោះស្រាយបណ្តឹងតវ៉ារបស់អ្នកដេញថ្លៃ។

**មាត្រា២២.-**

គណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ាលទ្ធកម្មមានសិទ្ធិបដិសេធ ឬទទួលដោះស្រាយ ឬបង្វិលបណ្ដឹងតវ៉ាទៅសាមីស្ថាប័នអនុវត្តលទ្ធកម្មដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ ដោយត្រូវជូនដំណឹងដល់អ្នកប្ដឹងតវ៉ាតាមរយៈលិខិតអនុសិដ្ឋ ឬលិខិតប្រគល់ផ្ទាល់ដៃដោយមានបញ្ជាក់មូលហេតុច្បាស់លាស់ក្នុងរយៈពេល ៣ (បី)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យប្ដឹងតវ៉ា។

**មាត្រា២៣.-**

ក្នុងករណី គណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ាលទ្ធកម្មបដិសេធការដោះស្រាយបណ្ដឹងតវ៉ា ឬមិនបានជូនដំណឹងដល់អ្នកប្ដឹងតវ៉ាតាមរយៈពេលកំណត់ក្នុងមាត្រា២២នៃអនុក្រឹត្យនេះ អ្នកប្ដឹងតវ៉ាមានសិទ្ធិដាក់ពាក្យប្ដឹងតវ៉ាទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា២៤.-**

ចំពោះពាក្យប្ដឹងតវ៉ាដែលពុំមានព័ត៌មានឬឯកសារភស្តុតាងគ្រប់គ្រាន់ គណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ាលទ្ធកម្មត្រូវស្នើឱ្យអ្នកប្ដឹងតវ៉ាផ្ដល់ព័ត៌មាន ឬឯកសារភស្តុតាងបន្ថែមក្នុងរយៈពេល ៥ (ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទចេញសេចក្ដីជូនដំណឹងស្ដីពីការទទួលដោះស្រាយបណ្ដឹងតវ៉ា។ ផុតកាលកំណត់នេះ គណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ាលទ្ធកម្មមិនដោះស្រាយបណ្ដឹងតវ៉ាឡើយ។

**មាត្រា២៥.-**

គណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ាលទ្ធកម្មត្រូវពិនិត្យនិងដោះស្រាយបណ្ដឹងតវ៉ាក្នុងរយៈពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីថ្ងៃជូនដំណឹងស្ដីពីការសម្រេចទទួលដោះស្រាយបណ្ដឹងតវ៉ា ឬ១០(ដប់) ថ្ងៃ នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទដែលអ្នកប្ដឹងតវ៉ាផ្ដល់ព័ត៌មានឬឯកសារគ្រប់គ្រាន់។

**មាត្រា២៦.-**

ការដោះស្រាយបណ្ដឹងតវ៉ាត្រូវគោរពតាមគោលការណ៍និងត្រូវមានការបញ្ជាក់ឱ្យបានច្បាស់លាស់អំពីកម្មវត្ថុនៃការប្ដឹងនិងលទ្ធផលនៃការដោះស្រាយបណ្ដឹងដូចមានចែងក្នុងមាត្រា ១៥ នៃអនុក្រឹត្យនេះ។ ចំពោះសេចក្ដីសម្រេចលើបណ្ដឹងតវ៉ាត្រូវអនុលោមតាមមាត្រា១៧ នៃអនុក្រឹត្យនេះ។

**មាត្រា២៧.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុត្រូវផ្ញើសេចក្ដីសម្រេចស្ដីពីការដោះស្រាយទៅអ្នកប្ដឹងតវ៉ានិងចម្លងជូនសាមីស្ថាប័នអនុវត្តលទ្ធកម្មដែលអនុវត្តកិច្ចលទ្ធកម្មផ្ទាល់ មួយច្បាប់។

**មាត្រា២៨.-**

អ្នកប្ដឹងតវ៉ាដែលមិនយល់ព្រមនឹងសេចក្ដីសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានចែងក្នុងមាត្រា២៧ នៃអនុក្រឹត្យនេះ មានរយៈពេល ១០ (ដប់)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទចេញសេចក្ដីសម្រេចរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីប្ដឹងបន្តទៅតុលាការមានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។ ផុតកាលកំណត់នេះ អ្នកប្ដឹងតវ៉ាត្រូវបាត់បង់សិទ្ធិប្ដឹងទៅតុលាការមានសមត្ថកិច្ច។

## ជំពូកទី៤
## បទប្បញ្ញត្តិផ្សេងៗ

**មាត្រា២៩.-**

ក្នុងករណីចាំបាច់ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុអាចចេញប្រកាស ឬសារាចរណែនាំបន្ថែមដើម្បីពង្រឹងនិងធានាប្រសិទ្ធភាពក្នុងការអនុវត្តអនុក្រឹត្យនេះ។

## ជំពូកទី៥
## ទោសប្បញ្ញត្តិ

**មាត្រា៣០.-**

ក្នុងករណីរកឃើញថា អ្នកប្តឹងតវ៉ាមានគោលបំណងរំខានដើម្បីធ្វើឱ្យមានការកែប្រែ ឬពន្យារពេលនៃដំណើរការលទ្ធកម្មសាធារណៈ ដោយបានដាក់ពាក្យប្តឹងមិនមានមូលដ្ឋានច្បាប់ច្បាស់លាស់ ឬបានភ្ជាប់ឯកសារភស្តុតាងក្លែងបន្លំ ឬមិនត្រឹមត្រូវ អ្នកប្តឹងតវ៉ាត្រូវប្រឈមនឹងទោសទណ្ឌដូចមានចែងក្នុងមាត្រា៦៦ ជំពូកទី១២ "ទោសប្បញ្ញត្តិ" នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២។

**មាត្រា៣១.-**

អ្នករាជការសាធារណៈគ្រប់លំដាប់ថ្នាក់ដែលបានប្រព្រឹត្តល្មើសនឹងបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ឬត្រូវបានរកឃើញថាមានការពាក់ព័ន្ធនឹងការប្រព្រឹត្តមិនប្រក្រតីនៅក្នុងដំណើរការនៃការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មត្រូវទទួលទណ្ឌកម្មរដ្ឋបាលស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាន។ ទណ្ឌកម្មរដ្ឋបាលនេះមិនមែនជាឧបសគ្គសម្រាប់ការចោទប្រកាន់និងការផ្តន្ទាទោសព្រហ្មទណ្ឌស្របតាមច្បាប់និងបទប្បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជាឡើយ។

**មាត្រា៣២.-**

អ្នកប្តឹង និងបុគ្គលពាក់ព័ន្ធផ្សេងទៀតដែលត្រូវបានរកឃើញថាបានប្រព្រឹត្តអំពើពុករលួយ អំពើបន្លំ អំពើឃុបឃិត ឬអំពើបង្ខិតបង្ខំនៅក្នុងដំណើរការនៃការដោះស្រាយបណ្តឹងតវ៉ាលទ្ធកម្មត្រូវផ្តន្ទាទោសដោយយោងតាមក្រមព្រហ្មទណ្ឌនិងបទប្បញ្ញត្តិជាធរមាននៅព្រះរាជាណាចក្រកម្ពុជា។

បទល្មើសពុករលួយដូចដែលបានចែងក្នុងកថាខណ្ឌទី១ខាងលើនេះ ត្រូវស្ថិតនៅក្រោមសមត្ថកិច្ចរបស់អង្គភាពប្រឆាំងអំពើពុករលួយដូចមានចែងក្នុងមាត្រា៧៣ នៃច្បាប់ស្តីពីលទ្ធកម្មសាធារណៈដែលបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២។

## ជំពូកទី៦
## អវសានប្បញ្ញត្តិ

**មាត្រា៣៣.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៣៤.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង ប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ប្រធានគ្រប់អង្គភាពរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ពុធ ៧កើត ខែផល្គុន ឆ្នាំរកា នព្វស័ក ព.ស ២៥៦១
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២១ ខែកុម្ភៈ ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន
សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

បណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ